## ភាពរីកចំរើនរបស់ក្រុមសន្សំប្រាក់



គំរោងសន្សំប្រាក់ដើម្បីអាស្រ័យលើខ្លួនឯងបានចាប់ផ្តើមអនុវត្តន៏សាកល្បងនៅក្នុងឆ្នាំ ២00៣ ក្រោយពីការផ្សព្វផ្សាយគំរោង និងការសិក្សាពីលទ្ធភាពជាក់ស្តែងពីការរស់នៅរបស់ប្រជាជននៅតាមមូលដ្ឋានឃើញថា : កសិករមានតំរូវការច្រើនទៅលើការខ្ចីប្រាក់ពីខាងក្រៅ ដែលមានអត្រាការប្រាក់ខ្ពស់ ដូចនេះវាធ្វើអោយជីវភាពគ្រួសាររបស់ពួកគាត់ជួបបញ្ហាខ្វះខាតច្រើន។
ដោយឃើញស្ថានភាពជាក់ស្តែងរបស់កសិករ នៅឆ្នាំ ២00៥ គំរោងក៏បានធ្វើការពង្រីកការផ្សព្វផ្សាយរហូតដល់ ១0 ខេត្ត ។ ចំពោះការខ្ចីប្រាក់ពីខាងក្រៅដែលមានអត្រាការប្រាក់ខ្ពស់បានធ្វើឱ្យមានការរីកចំរើន និងមានការទទួលយកច្រើន ព្រោះដោយយល់ឃើញថាវាមានប្រយោជន៏ខ្លាំងដល់កសិករតាមមូលដ្ឋាន នៅខែសីហា ឆ្នាំ ២00៥ សេដាក បានចាប់ផ្តើមគាំទ្រគំរោងនេះដើម្បីអោយមានដំណើរការរហូតមកដល់សព្វថ្ងៃនេះ ។ គំរោងនេះមានតំណើរការទៅបានរហូតសព្វថ្ងៃក្រោមការឧបត្ថម្ភថវិកាពីអង្គការ អុកស្វាមអាមេរិក (Oxfam America) ។ ជាក់ស្តែងភាពរីកចំរើន គិតមកដល់ខែកញ្ញា ឆ្នាំ ២00៨ ក្រុមសន្សំប្រាក់មានចំនួន ៣៥៨0 ក្រុម បាននឹងកំពុងធ្វើការផ្សព្វផ្សាយទៅដល់ភូមិចំនួន ២0២៩ ភូមិ ស្ថិតនៅក្នុងឃុំចំនួន ៤១២ ក្នុងស្រុកចំនួន ៨0 ស្រុក និងខេត្តចំនួន ១៧ ខេត្តក្រុង។ ចំនួនសមាជិកសរុបមានចំនួន ៥៣ ១២៣ នាក់ ( ស្ត្រី ៣២ ៦៣0 នាក់) និងមានទុនសរុបប្រមាណជា ៥ ៣៧0 000 000 រៀល ឬ ប្រមាណ ១,៣ លានដុល្លារអាមេរិក។